# មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជា

**Cambodian Centre for Applied Philosophy and Ethics**

*challenging you critically to shape your world!*

## ប្រវត្តិរបស់មជ្ឈមណ្ឌល

មជ្ឈមណ្ឌលទស្សនវិជ្ជា អនុវត្តន៍និងសីលធម៌កម្ពុជា "CAMCAPE" គឺជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យមួយដែលមិនរកប្រាក់ចំនេញមិនធ្វើនយោបាយដែលបានបង្កើតឡើងដោយបញ្ញវន្តខ្មែរមួយក្រុមនៅខែវិច្ឆិកា ឆ្នាំ២០០៦ និងបានចុះឈ្មោះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៧។ មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជា ជាអង្គការមួយដែលធ្វើការងារផ្នែកអប់រំ ស្រាវជ្រាវ តស៊ូមតិ និង ផ្តល់ប្រឹក្សាដោយបំពេញមុខងារជា ធនាគារគំនិត "Think Tank" ដើម្បីផ្តល់នូវការឆ្លុះ បញ្ចាំងតាមបែបទស្សនវិជ្ជានិងសីលធម៌ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការគិតពិចារណារ ស្មារតីនៅក្នុងប្រទេសកម្ពុជា។

## ទស្សនៈវិស័យ

មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជាមានទស្សនៈវិស័យចង់ឃើញសង្គមមួយដែលមានយុត្តិធម៌ សន្តិភាព និងចីរភាពដែលមនុស្សរស់នៅប្រកបដោយភាពថ្លៃថ្នូរពេញលេញ និងគតិបណ្ឌិត។




*"ទុក្ខរបស់ប្រជារាស្ត្រគឺជាទុក្ខរបស់ព្រះមហាក្សត្រ។"*

## បេសកកម្ម

មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជាមានបេសកកម្មលើកកំពស់ការសិក្សាការស្រាវជ្រាវការសន្ទនាជាសាធារណៈ និងការអនុវត្តទស្សនវិជ្ជានិងសីលធម៌ វប្បធម៌សន្តិភាពនៅក្នុងប្រទេសកម្ពុជាដែលដឹកនាំអោយមនុស្សទូទៅ ជាពិសេសប្រជាជនកម្ពុជាក្នុងការគិតពិចារណាអោយបានស៊ីជំរៅ និងប្រកបដោយសីលធម៌ក្នុងការកសាងសង្គមជាតិរបស់យើង។

## គោលដៅ

មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជាមានគោលដៅលើកកំពស់តំលៃនិងការប្រើប្រាស់ទស្សនវិជ្ជានិងសីលធម៌ដើម្បីលើកកំពស់តំលៃសង្គមនិងមនុស្សជាតិដើម្បីសំរេចបាននូវការរស់នៅប្រកបដោយភាពសុខដុមរម្យនានិងការអភិវឌ្ឍប្រកបដោយចីរភាព។



## វត្ថុបំណង

១.ដើម្បីលើកកំពស់ការស្រាវជ្រាវ ការសិក្សាទស្សនវិជ្ជា និងសីលធម៌ទាំងទ្រឹស្តីនិងការអនុវត្តនៅក្នុងសង្គមកម្ពុជា ដើម្បីចូលរួមចំនែកដោះស្រាយបញ្ហារបស់ប្រទេសជាតិដែលទើបតែងើបផុតពីសង្គ្រាមនិងកសាងឡើងវិញនូវតំលៃនៃការគិតនិងការរស់នៅប្រកបដោយភាពត្រឹមត្រូវរបស់ប្រជាជនកម្ពុជា។

២.ដើម្បីបង្កើនការចាប់អារម្មណ៍របស់សាធារណៈជនទូទៅ ជាពិសេសយុវជនអោយស្គាល់ពីតំលៃនៃទស្សនវិជ្ជានិងសីលធម៌ក្នុងការដោះស្រាយបញ្ហាសំខាន់ៗក្នុងជីវិតនៅក្នុងពិភពលោកដែលពោរពេញទៅដោយការផ្លាស់ប្តូរ។

៣.ដើម្បីលើកកំពស់ការទទួលខុសត្រូវរួម សេរីភាព សន្តិភាព ការសន្ទនា យុត្តិធម៌សង្គម និង ការរស់នៅជាមួយគ្នាប្រកបដោយសីលធម៌នៅក្នុងចិត្តនិងកាយ។

៤.ដើម្បីចែករំលែកចំណេះដឹង ជំនាញ និងឥរិយាបទល្អៗដល់សាធារណៈជន ជាពិសេសជាមួយនឹងយុវជនដើម្បីអោយគេពិនិត្យការរស់នៅនិងការគិតរបស់គេក្នុងផ្លូវវិជ្ជមាននិងប្រកបដោយការច្នៃប្រឌិត។

៥.ដើម្បីបណ្តុះបណ្តាលអ្នកដឹកនាំ និងអ្នកគិតដែលមានការគិតពិចារណានិងភាពច្នៃប្រឌិតខ្ពស់នៅក្នុងសង្គមប្រជាធិប្បតេយ្យ និងសាកលភាវូបនីយ-កម្ម។

## សកម្មភាព

១.ចងក្រងនិងចែកចាយសៀវភៅ ព្រឹត្តិប័ត្រ ភាព-យន្តអប់រំខ្លីៗ និងឯកសារនានាដែលទាក់ទងនឹងទស្សនវិជ្ជានិងសីលធម៌។

២.ចងក្រងនិងផ្សព្វផ្សាយអត្ថបទជាប្រចាំស្តីពីបញ្ហានៅក្នុងសង្គមបច្ចុប្បន្នតាមរយៈព្រឹត្តបត្រ និងការផ្សព្វផ្សាយតាមរយៈអ៊ីនធឺណែត និងអ៊ីម៉ែលដោយការឆ្លុះបញ្ចាំងតាមបែបទស្សនវិជ្ជានិងសីលធម៌។

៣.ធ្វើបាឋកថា វគ្គបណ្តុះបណ្តាល វេទិកាសាធារណៈ សិក្ខាសាលា សន្និសិទ្ធិជាមួយនឹងក្រុមគោលដៅ និងសាធារណៈជន ជាពិសេសយុវជនដើម្បីបង្ហាញពីសារៈសំខាន់នៃការអនុវត្តគោលការណ៍ទស្សនវិជ្ជានិងសីលធម៌នៅក្នុងការដោះស្រាយបញ្ហានៅក្នុងសង្គម។

៤.បង្កើតបណ្តាញអោយបានរឹងមាំជាមួយនឹងសមា-ជិក មិត្តភក្តិ អ្នកគាំទ្រនៅក្នុងប្រទេសដើម្បីលើកកំពស់ការចាប់អារម្មណ៍របស់សាធារណៈជនអំពីតំលៃនិងភាពចាំបាច់នៃទស្សនវិជ្ជា និងសីលធម៌ព្រមទាំងការអនុវត្តរបស់វានៅក្នុងការរស់នៅប្រចាំថ្ងៃ។

៥.សហការយ៉ាងសកម្មជាមួយនឹងអង្គការនានាទាំងនៅកម្ពុជា និងបរទេសដែលមានកម្មវត្ថុប្រហាក់ប្រហែលគ្នាក្នុងការសំរេចបាននូវបេសកកម្មរបស់មជ្ឈមណ្ឌល។

## ព័ត៌មានលំអិតសូមទាក់ទង


មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌កម្ពុជា
ផ្ទះលេខ៤ ផ្លូវបុរីសូនី សង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ ភ្នំពេញ
ប្រអប់សំបុត្រ P.O Box 2058 ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: +855 (0)12 766 364/ (0)12 635 211
អ៊ីម៉ែល : camcape@gmail.com
chanroeunkh@gmail.com
គេហទំព័រ: www.camcape.org


*"បើអ្នកគិតបែបណា ជីវិតរបស់អ្នកនឹងបែបនោះ។"*

- ព្រះពុទ្ធសមណគោត្តម

*"ជីវិតដែលមិនស្គាល់ខ្លួនឯងគឺជាជីវិតដែលគ្មានន័យ។"*

- សូក្រាត

អនាគតរបស់ប្រទេសកម្ពុជាពឹងផ្អែកទាំងស្រុងទៅលើគុណភាពនៃការគិតរបស់ប្រជាជនកម្ពុជា។